ព្រះរាជាណាចក្រកម្ពុជា - 86 -

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការ កំពូល

សំណុំរឿង ព្រហ្មទណ្ឌ

លេខ : ០៧

ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០០

សាលដីកា

លេខ : ០៣

ចុះថ្ងៃទី ០១ ខែ មិនា ឆ្នាំ ២០០០

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

ក្នុងបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០០ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះ ដូចតទៅ :

១- ឯកឧត្តម ឌិត មុន្ទី ជាប្រធាន
២- លោក ឈឹម ស៊ីផល ចៅក្រម
៣- លោក ឃស់ សូខឿន ចៅក្រម របាយការណ៍
៤- លោក ស៊ុន ឌឹម ចៅក្រម
៥- លោក ជីវ កេង ចៅក្រម

ក្រឡាបញ្ជី លោក ទឹម សង្វារិទ្ធ

- តំណាងមហាអយ្យការ លោក ជួន ស៊ុនឡេង ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ ១៤ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០០ របស់ សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ ០៧ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០០០ របស់ តុលាការកំពូល ។

ពីបទ : ឆបោក ប្រព្រឹត្តនៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី ៣១ និង ០១ ខែ ០៨ និង ០៩ ឆ្នាំ ១៩៩៩ បទល្មើសដែលមានចែងតាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- ជនជាប់ចោទឈ្មោះ ប៉ុក សុខា ជា " ម្ចាស់បណ្តឹងសាទុក្ខ " ភេទប្រុស អាយុ ៣១ ឆ្នាំ ជាតិខ្មែរ មុខរបរនាយកក្រុមហ៊ុន វ៉ាន់ឌីពាណិជ្ជ ។ ទីលំនៅសព្វថ្ងៃផ្ទះលេខ១៣៧ រប ផ្លូវលេខ ៣០៦ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ ប៉ុក វ៉ាត "រស់" ម្តាយឈ្មោះ ឯក-ចាន់ថាត "រស់" នៅលីវ ។ ឃុំខ្លួនថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៩៩ ។

- មេធាវី គ្មាន

- ដើមបណ្តឹងរដ្ឋប្បវេណី លោក ម៉ែត ទេវីរុស ភេទប្រុស អាយុ ៥៦ ឆ្នាំ ជនជាតិបារាំង មុខរបរនាយកក្រុមហ៊ុនតូតាល់កម្ពុជា ការិយាល័យលេខ ១២១ ផ្លូវព្រះនរោត្តម ក្រុងភ្នំពេញ " ដែល បន្តទៅក្រោយលោក អាទ្រៀណាន់ឌីស៊ីល្វាស្ត្រី ជានាយកថ្មី របស់ក្រុមហ៊ុនតូតាល់កម្ពុជា ។/

-មេធាវីគ្មាន

- តាមបណ្តឹងសាទុក្ខលេខ ០៦ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ របស់ លោកសៅ វីតា ការពារអោយជនជាប់ចោទឈ្មោះ ប៉ុក សុទ្ធា ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ១៤ ចុះថ្ងៃទី១៨ ខែ មករា ឆ្នាំ ២០០០របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- តាមពាក្យបណ្តឹងចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៩ របស់ក្រុមហ៊ុនតូតាល់កម្ពុជា តំណាង ដោយលោក ម៉ែតវៀល នាយកក្រុមហ៊ុន បានប្តឹងពីឈ្មោះ ប៉ុក សុទ្ធា ជាប្រធានក្រុមហ៊ុន វ៉ាន់នីពាណិជ្ជ ពីបទ ប្រើប្រាស់មូលប្បទានប័ត្រ គ្មានប្រាក់ ដែលមានលេខ :

- ៣៧៧៣៤៦ ចុះថ្ងៃទី ៣១ - ០៨ - ១៩៩៩ តំលៃ ១០.០០០ " មួយម៉ឺនដុល្លារអាមេរិក "
- ៣៧៧៣៤៧ ចុះថ្ងៃទី ៣១ - ០៨ - ១៩៩៩ តំលៃ ២០.០០ " ពីរពាន់ដុល្លារអាមេរិក "
- ៣៧៧៣៤៨ ចុះថ្ងៃទី ០២ - ០៩ - ១៩៩៩ តំលៃ ១០.០០០ " មួយម៉ឺនដុល្លារអាមេរិក "
- ៣៧៧៣៤៩ ចុះថ្ងៃទី ០១ - ០៩ - ១៩៩៩ តំលៃ ១៣.០០០ " មួយម៉ឺនបីពាន់ដុល្លារអាមេរិក "

ក្នុងរឿងនេះខ្លួនសុំអោយតុលាការផ្តន្ទាទោសឈ្មោះ ប៉ុក សុទ្ធា តាមផ្លូវច្បាប់ សុំទាមទារ ប្រាក់ចំនួន ៦៥១៤៤ ដុល្លារអាមេរិក និងទាមទារជំងឺចិត្តខាតបង់ពេលវេលា ចំនួន ៥០០០ដុល្លារអាមេរិក ពីឈ្មោះ ប៉ុក សុទ្ធា ។

- បានឃើញដីកាសំរេចឃុំខ្លួនលេខ ៩៤០ ចុះថ្ងៃទី ០៨ - ១២ - ១៩៩៩ របស់ចៅក្រមស៊ើបអង្កេត តុលាការក្រុងភ្នំពេញ ។

- បានឃើញដីកាសំរេចលេខ ៥៤៩៣ តក្រ ចុះថ្ងៃទី ២០ - ១២ - ១៩៩៩ បដិសេធពាក្យសុំធានាអោយឈ្មោះ ប៉ុក សុទ្ធានៅក្រៅឃុំ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៣៤ "ប" ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ របស់លោក សៅ - វីតា មេធាវីការពារអោយជនជាប់ចោទឈ្មោះ ប៉ុក សុទ្ធា ដែលប្តឹងតវ៉ាពីដីកាសំរេចលេខ ៥៤៩៣តក្រ ចុះថ្ងៃទី ២០ - ១២ - ១៩៩៩ របស់ចៅក្រមស៊ើបអង្កេត តុលាការក្រុងភ្នំពេញ ។

- បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អម សាលាឧទ្ធរណ៍ថា :

១ - ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៧ - ១២ - ១៩៩៩ របស់ លោក សៅ - វីតា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយនឹង គតិច្បាប់ ។

២ - តំកល់ដីកាសំរេចលេខ ៥៤៩៣ ចុះថ្ងៃទី ២០ - ១២ - ១៩៩៩ របស់ចៅក្រមស៊ើបអង្កេត តុលាការក្រុងភ្នំពេញ ទុកជាបានការ ។

- បានឃើញ សាលដីកាព្រហ្មទណ្ឌ លេខ ១៤ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០០ របស់ សាលាឧទ្ធរណ៍ ដែលបានសំរេច :

១ - ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៧ - ១២ - ១៩៩៩ របស់លោក សៅ - វីតា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយ នឹងគតិច្បាប់ ។

២ - តំកល់ដីកាសំរេចលេខ ៥៤៩៣ ចុះថ្ងៃទី ២៧ - ១២ - ១៩៩៩ របស់ចៅក្រម

ស៊ើបអង្កេត តុលាការក្រុងភ្នំពេញ ទុកជាបានការ ។

៣ - សាលដីកានេះជំនុំជំរះ នៅថ្ងៃទី ១២ - ០១ - ២០០០ ចំពោះមុខមេធាវីឈ្មោះ សៅ រីតា - ពិន ម៉ាលីណា និង ចំពោះមុខជនជាប់ចោទ និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ១៨ - ០១ - ២០០០ ចំពោះមុខ មេធាវីឈ្មោះសៅ រីតា - កំបាំងមុខមេធាវីពិន ម៉ាលីណា ដែលចាត់ទុកជាចំពោះមុខ បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

- បានឃើញ បណ្តឹងសាទុក្ខលេខ ០២ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ របស់ លោក សៅ រីតា មេធាវីការពារអោយជនជាប់ចោទឈ្មោះ ប៉ុក សុទ្ធា ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ១៥ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០០ របស់ សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

- បានឃើញ សារណា ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០០ របស់ឈ្មោះ ប៉ុក សុទ្ធា ជាម្ចាស់បណ្តឹងសាទុក្ខ ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានឃើញ សារណាឆ្លើយតប ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០០ របស់ឈ្មោះ អាទិ្យចសាន់ឌីគីល្លានស្តី ជាចុងបណ្តឹងសាទុក្ខធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានស្តាប់របាយការណ៍ របស់ ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋាន របស់ តំណាងមហាអយ្យការ អម តុលាការកំពូលថា : ការសុំអនុញ្ញាតអោយនៅក្រៅឃុំជាបណ្តោះអាសន្ន របស់ជនជាប់ចោទ មានលក្ខណៈត្រឹមត្រូវ ព្រោះថាបទល្មើសនេះជាបទល្មើសមជ្ឈិម ហើយម្យ៉ាងទៀតការដែលជនជាប់ចោទដាក់ប្រាក់ធានា និង ប្លង់ដីនៅក្រុមហ៊ុនតួតាស់ មានលក្ខណៈធួនល្មមដែលអាចអោយនៅក្រៅឃុំបាន ហើយជនជាប់ចោទ មានទីលំនៅច្បាស់លាស់ ជាប្រធានក្រុមហ៊ុន ឯការស៊ើបអង្កេតរបស់ តុលាការ ក៏បានមូលសព្វគ្រប់ហើយដែរ ដូច្នេះសូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ផង ។

- បានស្តាប់ ចំលើយអះអាងរបស់លោក ប៉ុក សុទ្ធា ជាម្ចាស់បណ្តឹងសាទុក្ខនៅពេលជំនុំជំរះថា : ដោយខ្ញុំបាទជាប់មានភារកិច្ច ចុះកិច្ចសន្យាជាមួយក្រសួងសង្គមកិច្ច ដូច្នេះខ្ញុំបាទសូមសំណូមពរដល់ក្រុមប្រឹក្សាជំនុំជំរះ មេត្តាជួយអោយខ្ញុំបាទបាននៅក្រៅឃុំ ដើម្បីរកប្រាក់សងដល់ដើមបណ្តឹងរដ្ឋប្បវេណី ។

- បានស្តាប់ អំណានសារណារបស់ លោក អាទិ្យចសាន់ឌីគីល្លានស្តី ជាចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះ ។

- បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែម នាពេលសវនាការរបស់តំណាងមហាអយ្យការ អម តុលាការកំពូលថា : តំណាងមហាអយ្យការ ពុំមានយោបល់អ្វីបន្ថែមទៀតទេ សូមរក្សាសេចក្តីសន្និដ្ឋាន នៅដដែល ។

- ក្រោយពីបានស្តាប់ របាយការណ៍របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចំលើយដោះសារ របស់ជនជាប់ចោទ និង សារណារបស់ដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ០២ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ របស់លោក សៅ វីតា មេធាវីការពារជនជាប់ចោទឈ្មោះប៊ុក សុទ្ធា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៥ នៃច្បាប់ស្តីពីការរៀបចំ និង សកម្មភាពរបស់ សាលាជំរះក្តី ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចសេចក្តី ដោយអាងហេតុថា ប្រាក់ និង ប្លង់ដីដាក់ធានានោះ ពុំទាន់មានសុពលភាព និងប្រាក់ដែលបានទទួលនោះជាការពុំត្រឹមត្រូវទេ ពីព្រោះជនជាប់ចោទបានដាក់ប្រាក់ និងប្លង់ដីធានា និងសុខចិត្តសងក្នុងមួយខែចំនួន ៣០០០ដុល្លារអាមេរិក ទៀងទាត់ ខែរហូតគ្រប់ចំនួនប្រាក់ជំពាក់ ហើយដើមបណ្តឹងរដ្ឋប្បវេណីក៏សុខចិត្តយល់ព្រម តាមកិច្ចសន្យាធានា ចុះថ្ងៃទី ១៥ - ០១ - ២០០០ .នោះ រួចហើយដែរ ។

- យល់ឃើញថា ជនជាប់ចោទមានមុខរបរ និងទីលំនៅត្រឹមត្រូវ ឯការស៊ើបអង្កេតក៏មូលហើយដែរ ដែលពុំអាចធ្វើអោយប៉ះពាល់ដល់និតិវិធីរបស់តុលាការ គួរអនុញ្ញាតអោយជនជាប់ចោទនៅក្រៅឃុំជាបណ្តោះអាសន្នបាន ។

- យល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណី បានធ្វើសារណាការពារទៀងក្តីរបស់លោករួចហើយ ប៉ុន្តែពុំបានចូលរួមនាសវនាការនេះទេ ដូច្នេះ តុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខលោកចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១៥ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានការខុសឆ្គងទាំងទំរង់ និង គតិច្បាប់ ។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី ចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែចាត់ទុកជាចំពោះមុខ ៖

១ - ទទួលបណ្តឹងសាទុក្ខលេខ០២ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ របស់លោក សៅ វីតា មេធាវីការពារអោយជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២ - ទុកជាមោឃៈ សាលដីកាព្រហ្មទណ្ឌលេខ ១៥ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ២០០០



៣៧

របស់សាលាឧទ្ធរណ៍ ទាំងមូលដោយឥតបង្អិល ។

៣_ អនុញ្ញាតអោយជនជាប់ចោទឈ្មោះ ប៊ុក សុទ្ធា ភេទប្រុស អាយុ ៣១ ឆ្នាំ ទីលំនៅផ្ទះលេខ ៣៧ បេ ផ្លូវលេខ ៣០៦ សង្កាត់បឹងកេងកងទី ១ ខណ្ឌចំការមន ក្រុងភ្នំពេញ ជាប្រធានក្រុមហ៊ុនម៉ាច់ឌីពាណិជ្ជ នៅក្រៅឃុំជាបណ្ដោះអាសន្ន បើពុំត្រូវជាប់ឃុំខ្លួនពីបទអ្វីផ្សេង ទៀតទេ ។

៤_ បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ១០៧ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០០ របស់ តុលាការកំពូល ទៅតុលាការក្រុងភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធី ។

៥_ សាលដីកានេះប្រកាសនាសវនាការ ជាសាធារណៈនៅថ្ងៃទី ១ ខែ មិនា ឆ្នាំ ២០០០ ។/